ព័ត៌មានខាងក្រោមនេះគឺអនុលោមទៅតាមមាត្រាទី២០នៃច្បាប់ធានារ៉ាប់រងរបស់ព្រះរាជាណាចក្រកម្ពុជា ឬការធ្វើវិសោធនកម្មផ្សេងៗ ។ លោកអ្នកត្រូវបង្ហាញនៅក្នុងពាក្យស្នើសុំការធានារ៉ាប់រងនេះដោយស្មោះត្រង់នូវព័ត៌មានពិតប្រាកដដែលលោកអ្នកដឹង ឬគួរតែដឹង បើមិនដូច្នោះទេកិច្ចសន្យាធានារ៉ាប់រងដែលបានចេញអាចចាត់ទុកជាមោឃៈ ។

ឈ្មោះអ្នកស្នើសុំ : ______________________________

វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ឬលេខប័ណ្ណសំគាល់ខ្លួន : ______________________________

អាស័យដ្ឋានទំនាក់ទំនង : ______________________________

______________________________

ប្រភេទ/ មុខងារនៃអាជីវកម្ម : ______________________________

អ៊ីមែល : ______________________________

លេខទូរស័ព្ទ : ______________ លេខទូរសារ: ______________

រយៈពេលធានារ៉ាប់រង : ចាប់ផ្តើមពី ______________ រហូតដល់ ______________

ទីតាំងនៃហានិភ័យ : ______________________________

(ប្រសិនបើមានទីតាំងផ្សេងគ្នាពីអាស័យដ្ឋានទំនាក់ទំនង) ______________________________

១) តើលោកអ្នកមានផ្ទុកទំនិញដែលងាយនឹងឆេះ និង/ឬ ប្រកបដោយគ្រោះថ្នាក់នៅក្នុងបរិវេណអគារដែរឬទេ? O មាន O គ្មាន

២) តើធ្លាប់មានក្រុមហ៊ុនធានារ៉ាប់រងណាមួយបដិសេធ ច្រានចោលការបន្តកិច្ចសន្យាថ្មី ឬដាក់កំហិតចំពោះលក្ខខណ្ឌពិសេសណាមួយដែរឬទេ? O ធ្លាប់ O មិនធ្លាប់

៣) តើលោកអ្នកធ្លាប់ទទួលរងការបាត់បង់ និង/ឬ ធ្វើបណ្តឹងទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងណាមួយក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះដែរឬទេ? O ធ្លាប់ O មិនធ្លាប់

*ប្រសិនបើមានសូមផ្តល់ព័ត៌មានលំអិត.* ______________________________

ប្រព័ន្ធសុវត្ថិភាពក្នុងបរិវេណអគារ : O ប្រព័ន្ធកាមេរ៉ាសុវត្ថិភាព O សញ្ញាប្រកាសអាសន្នប្រឆាំងនឹងអំពើចោរកម្ម O បង្អួច/ទ្វារដែលមានចំរឹងដែក O សន្តិសុខយាមកាម២៤ម៉ោង

ប្រព័ន្ធការពារអគ្គិភ័យក្នុងបរិវេណអគារ : O សញ្ញាប្រកាសអាសន្នអគ្គិភ័យ O បំពង់ពន្លត់អគ្គិភ័យ O ទុយ៉ូទឹកសម្រាប់ពន្លត់អគ្គិភ័យ

**សេចក្តីប្រកាសអះអាង**

ខ្ញុំ/យើងខ្ញុំសូមប្រកាសអះអាងថា បរិវេណអគាររបស់ខ្ញុំ/យើងខ្ញុំសាងសង់ឡើងអំពីឥដ្ឋ និង/ឬបេតុង និង/ឬប្រក់ដំបូលដោយវត្ថុដែលមិនងាយនឹងឆេះព្រមទាំងស្ថិតនៅក្នុងសភាពល្អប្រសើរ ។

ខ្ញុំ/យើងខ្ញុំសូមប្រកាសអះអាងថា ព័ត៌មាននិងសេចក្តីបញ្ជាក់ខាងលើពិតជាត្រឹមត្រូវ និងពិតប្រាកដ និងព្រមព្រៀងប្រសិនបើព័ត៌មានខាងលើ ត្រូវបានបំពេញដោយបុគ្គលណាមួយដែលជាភ្នាក់ងាររបស់ខ្ញុំ/យើងខ្ញុំ ដែលមិនមែនជាភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ។

ខ្ញុំ/យើងខ្ញុំយល់ព្រមថា សេចក្តីប្រកាសអះ អាងនេះនឹងក្លាយជាមូលដ្ឋានគ្រឹះនៃកិច្ចសន្យារវាងក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក និង ខ្លួនខ្ញុំបាទ ឬខ្លួនពួកយើង និងត្រូវបានចាត់ទុកថាជាធាតុសំខាន់ដោយផ្អែកលើខចែង និង លក្ខខណ្ឌដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រង ។ រាល់ចម្លើយដែលបានផ្តល់ជូននៅក្នុងទម្រង់បែបបទស្នើសុំការធានារ៉ាប់រងនេះគឺពិតជាត្រឹមត្រូវ និងរាល់ការពិតទាំងឡាយដែលមានឥទ្ធិពលលើការវាយតម្លៃហានិភ័យរបស់អ្នកចេញប័ណ្ណធានារ៉ាប់រងត្រូវបានផ្តល់ជូន ។

______________________ ហត្ថលេខា និងការបញ្ជាក់អះអាង ______________

ហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ម្ចាស់គណនី ______________

ថ្ងៃ ខែ ឆ្នាំ : ______________ លេខគណនី ______________

ខិត្តប័ណ្ណនេះមិនមែនជាកិច្ចសន្យាធានារ៉ាប់រងទេ ។ ទោះបីជាយ៉ាងណាក៏ដោយសេចក្តីប្រកាសអះអាង និងការបង្ហាញព័ត៌មានទាំងអស់នឹងក្លាយទៅជាមូលដ្ឋានគ្រឹះនៃកិច្ចសន្យាធានារ៉ាប់រង ។ ខចែងជាក់លាក់ លក្ខខណ្ឌ និងករណីលើកលែងដែលត្រូវអនុវត្តចំពោះការធានារ៉ាប់រងនេះ គឺមានបញ្ជាក់ជូននៅក្នុងកិច្ចសន្យា ។

**អំពីការធានារ៉ាប់រងជាកញ្ចប់**

ការធានារ៉ាប់រងជាកញ្ចប់នេះត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការផ្នែកធានារ៉ាប់រងភាគច្រើនទៅលើការិយាល័យ និង ទីកន្លែងលក់រាយ ហើយតម្លៃវិញមានលក្ខណៈប្រកួតប្រជែង ។ ការទទួលខុសត្រូវដែលមាននៅក្នុងការធានារ៉ាប់រងជាកញ្ចប់នេះ គួរតែមានលក្ខណៈគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការធានារ៉ាប់រងភាគច្រើនរបស់លោកអ្នក ។ ការធានារ៉ាប់រងជាកញ្ចប់នេះមានដូចខាងក្រោម:

| | |
|---|---|
| ផ្នែកទី១ : ការធានារ៉ាប់រងជាមូលដ្ឋាន (កាតព្វកិច្ច) | - ការធានារ៉ាប់រងលើអគ្គិភ័យ និងហានិភ័យផ្សេងៗ<br>- ការធានារ៉ាប់រងលើគ្រោះថ្នាក់ចំពោះកម្មករនិយោជិត |
| ផ្នែកទី២ : ការធានារ៉ាប់រងបន្ថែម (ជាជម្រើស) | - ការធានារ៉ាប់រងលើការទទួលខុសត្រូវជាសាធារណៈ<br>- ការធានារ៉ាប់រងលើអំពើចោរកម្ម<br>- ការធានារ៉ាប់រងលើរូបិយវត្ថុក្នុងបរិវេណអគារ<br>- ការធានារ៉ាប់រងលើការដឹកជញ្ជូនរូបិយវត្ថុ<br>- ការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល |

ករណីលើកលែងខាងក្រោមនេះត្រូវបានអនុវត្តៈ

១. ការិយាល័យដែលដំណើរការក្នុងកុងទីន័រ
២. អ្នកម៉ៅការ
៣. សេវាកម្មផ្នែកនាំសំបុត្រ អ្នកបញ្ជូនទំនិញ អ្នកនាំទំនិញ ក្រុមហ៊ុនដឹកជញ្ជូន និងអាជីវកម្មពាក់ព័ន្ធដទៃទៀត
៤. គិញ/ អ្នកស៊ើបអង្កេត
៥. ការដ្ឋានសាងសង់ និង/ឬអាជីវកម្មតាមកប៉ាល់គ្រប់រូបភាព
៦. ព្រឹត្តិការណ៍/ ការតាំងពិព័ណ៌/ ការរៀបចំព្រឹត្តិការណ៍អ្វីមួយ
៧. ស្ថាប័នហិរញ្ញវត្ថុ
៨. អាជីវកម្មយានយន្ត
៩. ក្រុមហ៊ុនផ្តល់សេវាកម្មសន្តិសុខ
១០. អ្នកស៊ើបអង្កេត/ អ្នកត្រួតពិនិត្យហានិភ័យធានារ៉ាប់រង
១១. បរិវេណអគារដែលសំណង់មិនមែនជា ឥដ្ឋ/ ក្បឿង/ បេតុង និង/ឬទ្រព្យសម្បត្តិដែលរក្សាទុកក្នុងទីលំហ ឬដោយមិនមានបរិវេណរបង ឬសន្តិសុខយាមកាម
១២. បរិវេណអគារដែលមានសន្និធិលើសពី១០%នៃចំនួនទឹកប្រាក់ធានារ៉ាប់រងដោយផ្អែកលើផ្នែកទី១នៃការិយាល័យរួមគ្នាតែប៉ុណ្ណោះ ។

ការធានារ៉ាប់រងជាកញ្ចប់នេះមិនទទួលខុសត្រូវលើហានិភ័យដែលកើតឡើងនៅក្រៅបរិវេណអគារ លើកលែងតែក្នុងគោលបំណងដឹកជញ្ជូនទំនិញតែប៉ុណ្ណោះ ។

ប្រសិនបើលោកអ្នកមានបំណងចង់បន្ថែមនូវការធានារ៉ាប់រង និង/ឬស្វែងរកសេចក្តីបញ្ជាក់អះអាងបន្ថែមទៀត សូមទំនាក់ទំនងមកយើងខ្ញុំដោយផ្ទាល់ ។

**អំពីយើងខ្ញុំ**

ក្រោយពីការចាប់ផ្តើមប្រតិបត្តិការអាជីវកម្មកាលពីថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០០៧ យើងខ្ញុំបានបន្តពង្រីងវត្តមាននៅក្នុងប្រទេសកម្ពុជា ជាមួយនឹងសេវាកម្មផ្នែកធានារ៉ាប់រងយ៉ាងទូលំទូលាយ ។ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក គឺជាការវិនិយោគរួមគ្នារវាងធនាគារកម្ពុជាសាធារណៈ និងធនាគារសាធារណៈ របស់ប្រទេសម៉ាឡេស៊ី ដោយបានសហការជាមួយ LPI Capital តាមរយៈក្រុមហ៊ុនធានារ៉ាប់រង ឡុនប៉ាក ។ យុទ្ធសាស្ត្រក្នុងភាពជាដៃគូបានបោះជំហ៊ានសន្សឹមៗ ជាមួយបណ្តាញសាខាយ៉ាងទូលំទូលាយ និងរឹងមាំរបស់ធនាគារកម្ពុជាសាធារណៈ ព្រមទាំងជំនាញខាងវិស័យធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ឡុនប៉ាក ។ ក្រុមហ៊ុនធានារ៉ាប់រង ឡុនប៉ាក ត្រូវបានចាត់ជាក្រុមហ៊ុនដែលមានមូលដ្ឋានហិរញ្ញវត្ថុរឹងមាំកំរិត A- (ល្អប្រសើ) និង issuer credit rating of "a-" ដោយ A.M. Best Co., ដែលជាអង្គការវាយតំលៃផ្នែកសេវាកម្មលំដាប់ពិភពលោក ។

ក្នុងឆ្នាំ ២០០៩ ក្រុមហ៊ុនធានារ៉ាប់រង ឡុនប៉ាក បានទទួលរង្វាន់ពី Euromoney ដូចខាងក្រោម:

❶ ជាក្រុមហ៊ុនធានារ៉ាប់រងល្អជាងគេក្នុងប្រទេសម៉ាឡេស៊ី
❷ ជាក្រុមហ៊ុនធានារ៉ាប់រងល្អជាងគេក្នុងការដោះស្រាយបណ្តឹងទាមទារសំណង
❸ ជាអ្នកប្រឹក្សាល្អបំផុតសំរាប់ការផ្ទេរហានិភ័យធានារ៉ាប់រង
❹ ជាក្រុមហ៊ុនធានារ៉ាប់រងល្អបំផុតសំរាប់ការបង្កើតថ្មី
❺ ជាក្រុមហ៊ុនធានារ៉ាប់រងល្អបំផុតចំពោះតំលៃ
❻ ជាអ្នកផ្តល់ផលិតផលសេវាកម្មដែលស្ថិតក្នុងលំដាប់ល្អបំផុត

ក្នុងឆ្នាំ ២០១០ ក្រុមហ៊ុនធានារ៉ាប់រង ឡុនប៉ាក បានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងម៉ាឡេស៊ីទី១ដែលឈ្នះពានកិត្តិយស **"ក្រុមហ៊ុនធានារ៉ាប់រងទូទៅប្រចាំឆ្នាំ"** ដែលផ្តល់ដោយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍សម្រាប់ពានរង្វាន់ផ្នែកឧស្សាហកម្មធានារ៉ាប់រងប្រចាំឆ្នាំ ២០១០ ក្នុងការទទួលស្គាល់នូវចំណេះដឹងយ៉ាងស៊ីជំរៅលើផលិតផលធានារ៉ាប់រង ព្រមទាំងបច្ចេកវិទ្យាព័ត៌មានវិទ្យាដើម្បីបំពេញតំរូវការអតិថិជន ខណៈពេលដែលនៅតែរក្សាបាននូវស្ថេរភាពផ្នែកហិរញ្ញវត្ថុ ។

**ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក**

**CAMPU LONPAC INSURANCE**

# ដំណោះស្រាយធានារ៉ាប់រងដ៏ឆ្លាតវៃ



| ផ្នែក | វិសាលភាពនៃការធានារ៉ាប់រង | មុខងារនៃអគារ | កម្មវត្ថុនៃការធានារ៉ាប់រង/ដែនកំណត់នៃការទទួលខុសត្រូវ | អត្រាបុព្វលាភបន្ថែម | តំលៃធានារ៉ាប់រងបន្ថែម/កម្មករនិយោជិត | បុព្វលាភបន្ថែម | កំរិតមិនធ្វើសំណង |
|---|---|---|---|---|---|---|---|
| | | | | | | | |
| **ផ្នែកទី១: ការធានារ៉ាប់រងជាមូលដ្ឋាន (កាតព្វកិច្ច)** | **ការធានារ៉ាប់រងលើអគ្គិភ័យ និងហានិភ័យនានា**<br>ទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានា ដែលបណ្តាលមកពីអគ្គិភ័យ រន្ទះ និងហានិភ័យបន្ថែមផ្សេងទៀត ។ | ការិយាល័យ | អគារ: ២៥.០០០ ដុល្លារ<br>ការកែលំអរអគារ និងទ្រព្យសម្បត្តិផ្សេងទៀតរួមមានសន្និធិជាដើម: ៥.០០០ ដុល្លារ | 0.១១៧% | | | 0.៥% នៃតំលៃធានារ៉ាប់រងសរុប<br>អប្បបរមា: ៥០០ ដុល្លារ<br>អតិបរមា: ១.៥០០ ដុល្លារ |
| | | អាជីវកម្មលក់រាយ | អគារ: ២៥.០០០ ដុល្លារ<br>ការកែរលំអរអគារ និងទ្រព្យសម្បត្តិផ្សេងទៀតរួមមានសន្និធិជាដើម: ១០.០០០ ដុល្លារ | 0.១២៥% | | | |
| | **ការធានារ៉ាប់រងលើគ្រោះថ្នាក់ចំពោះកម្មករនិយោជិត**<br>ទទួលខុសត្រូវចំពោះមរណភាព និងពិការភាពជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់កើតឡើងក្នុងប្រទេសកម្ពុជា ។ | ការិយាល័យ/ អាជីវកម្មលក់រាយ | ទទួលខុសត្រូវរហូតដល់កម្មករនិយោជិតចំនួន២នាក់<br>មរណភាព: ១.០០០ ដុល្លារ<br>ពិការភាពជាអចិន្ត្រៃយ៍: ១.០០០ ដុល្លារ | ៥ ដុល្លារ សំរាប់ការបន្ថែមបុគ្គលិកម្នាក់ៗ | | | គ្មាន |
| **ផ្នែកទី២: ការធានារ៉ាប់រងបន្ថែម (ជាជម្រើស)** | **ការទទួលខុសត្រូវជាសាធារណៈ**<br>នឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងសំរាប់ការទទួលខុសត្រូវស្របច្បាប់ចំពោះរបួសលើរាងកាយដែលកើតឡើងចំពោះភាគីតតិយជន និងដែលជាប់ទាក់ទងនឹងអាជីវកម្មរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។ | ការិយាល័យ/ អាជីវកម្មលក់រាយ | ៧៥.០០០ ដុល្លារ សំរាប់ហេតុការណ៍នីមួយៗ មិនកំណត់ក្នុងអំឡុងពេលនៃការធានារ៉ាប់រងនីមួយៗ | ៨ ដុល្លារ សំរាប់ការបន្ថែមចំនួនទឹកប្រាក់ ១០.០០០ ដុល្លារ | | | ៥០០ ដុល្លារ |
| | **អំពើចោរកម្ម**<br>នឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងសំរាប់ការបាត់បង់ដែលបណ្តាលមកពីអំពើចោរកម្ម ឬចោរប្លន់ ខណៈពេលដែលទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងត្រូវបានរក្សាទុកក្នុងបរិវេណអគារដែលត្រូវបានធានារ៉ាប់រង ។ | | ៥.០០០ ដុល្លារ | 0.៥% | | | |
| | **រូបិយវត្ថុក្នុងបរិវេណអគារ**<br>ទទួលខុសត្រូវចំពោះការបាត់បង់ប្រាក់កាសខណៈពេលដែលរក្សាទុកក្នុងបរិវេណអគារ ។ | | ១.០០០ ដុល្លារ | ២% | | | |
| | **ការដឹកជញ្ជូនរូបិយវត្ថុ**<br>ទទួលខុសត្រូវចំពោះការបាត់បង់ប្រាក់កាសខណៈពេលដែលដឹកជញ្ជូនក្នុងប្រទេសកម្ពុជា ។ | | ១.០០០ ដុល្លារ | ១% | | | ២៥០ ដុល្លារ |
| **ផ្តល់ជូននូវការធានារ៉ាប់រងដោយឥតគិតថ្លៃសំរាប់ផ្នែកទី២: ការធានារ៉ាប់រងបន្ថែម** | | | | | | | |
| **ឥតគិតថ្លៃ** | **គ្រោះថ្នាក់បុគ្គល**<br>ទទួលខុសត្រូវចំពោះមរណភាព និងពិការភាពជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ដែលកើតឡើងគ្រប់ទីកន្លែងលើពិភពលោក ។<br>(សំរាប់ម្ចាស់ ឬនាយកម្នាក់) | ការិយាល័យ/ អាជីវកម្មលក់រាយ | មរណភាព: ២.៥០០ ដុល្លារ<br>ពិការភាពជាអចិន្ត្រៃយ៍: ២.៥០០ ដុល្លារ | ឥតគិតថ្លៃ | គ្មាន | គ្មាន | គ្មាន |

**ដំណោះស្រាយធានារ៉ាប់រងដ៏ឆ្លាតវៃ**

**ការជ្រើសរើសគម្រោង (បុព្វលាភប្រចាំឆ្នាំ)**

| | ការធានារ៉ាប់រងជាមូលដ្ឋាន | ការធានារ៉ាប់រងជាមូលដ្ឋាន + ការធានារ៉ាប់រងបន្ថែម |
|---|---|---|
| ការិយាល័យ : | ៥៥ ដុល្លារ ☐ | ១៩៥ ដុល្លារ ☐ |
| កន្លែងលក់រាយ : | ៦០ ដុល្លារ ☐ | ២០០ ដុល្លារ ☐ |

| | |
|---|---|
| បុព្វលាភបន្ថែម | ដុល្លារ |
| ការជ្រើសរើសគម្រោង(បុព្វលាភប្រចាំឆ្នាំ) | ដុល្លារ |
| មិនធានាលើអគារ (ការដកចេញ) | ( ) ដុល្លារ |
| បុព្វលាភធានារ៉ាប់រងសរុបដែលត្រូវបង់ | ដុល្លារ |

កំណត់ចំណាំ:

- បុព្វលាភធានារ៉ាប់រងអប្បរមាសម្រាប់កិច្ចសន្យាធានារ៉ាប់រងមួយគឺ ៥៥.០០ ដុល្លារ
- ប្រសិនបើអគារមិនត្រូវបានធានាទេ នោះទឹកប្រាក់ ១០ ដុល្លារនឹងត្រូវបានដកចេញពីបុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ
- ចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រងសំរាប់ផ្នែកទី១: អគ្គិភ័យដែលមានតំលៃលើសពី ១ លានដុល្លា និង/ឬ ផ្នែកទី២: ការទទួលខុសត្រូវជាសាធារណៈដែលមានតំលៃលើសពី ៥០០.០០០ ដុល្លារ គឺមិនអាចទទួលបាននូវការធានារ៉ាប់រងតាមរយៈកិច្ចសន្យានេះឡើយ
- សំរាប់ខចែង និងលក្ខខណ្ឌជាក់លាក់ សូមពិនិត្យមើលនៅក្នុងកិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុនយើងខ្ញុំ ។

BR-SISKH-1211/v1.0


**ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី**
ជាន់ទី៧ នៃអគារកម្ពុប៊ែង
ផ្ទះលេខ ២៣ ផ្លូវលេខ ១១៤ សង្កាត់ផ្សារថ្មី ២ ខ័ណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ ១៩៥៦
ទូរស័ព្ទ : + ៨៥៥ ២៣ ៩៦៦ ៥៦៦ ទូរសារ : ៨៥៥ ២៣ ៩៨៦ ២៧៣
លេខទូរស័ព្ទប្រចាំការ២៤ម៉ោង : ០១៦ ៨១០ ៩៩៩/ ០១៧ ៧៩៩ ៩០៣
អ៊ីមែល : enquiries@campulonpac.com.kh
គេហទំព័រ : www.campulonpac.com.kh